**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ចេញពីដែនដីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងការធ្វើប្រទានកម្មដីចំនួន ១.១២៤ ហិកតា ជូនប្រជាពលរដ្ឋកាន់កាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

- បានឃើញសារាចរ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការប្រឡងប្រណាំងកៃលំអសោភ័ណភាពខេត្តទូទាំងប្រទេស
- បានឃើញសារាចរលេខ ០៥ សរ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាលស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញរបាយការណ៍លេខ ៩៧ របក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ របស់អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- តាមសំណើលេខ ១០៥ លសចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា ១ ៖**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ឆ្នាំ ២០០២ និងធ្វើអនុបយោគមកជាដីឯកជនរបស់រដ្ឋ នូវផ្ទៃដីចំនួន ១.១២៨ ហ.ត (មួយពាន់មួយរយម្ភៃប្រាំបីហិកតា) ស្ថិតនៅក្នុងភូមិត្រពាំងស្ដៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត លើផ្ទៃដីចំនួន ១.១២៨ ហ.ត (មួយពាន់មួយរយម្ភៃប្រាំបីហិកតា) ដែលកំណត់តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 84 ដូចក្នុងផែនទី[1] និងចំណុចគោល នៃក្បាលដីនីមួយៗ ភ្ជាប់ក្នុងឧបសម្ព័ន្ធ I និងII នៃអនុក្រឹត្យនេះ និងដែលមាននិយាមកាដូចខាងក្រោម ៖

| ចំណុច | X | Y | ចំណុច | X. | Y | ចំណុច | X | Y |
|---|---|---|---|---|---|---|---|---|
| 1 | 419002 | 1197228 | 17 | 416497 | 1193359 | 33 | 415735 | 1196024 |
| 2 | 419395 | 1196859 | 18 | 415494 | 1193248 | 34 | 415754 | 1196073 |
| 3 | 419967 | 1196317 | 19 | 415500 | 1193453 | 35 | 415779 | 1196095 |
| 4 | 420611 | 1195933 | 20 | 415641 | 1193833 | 36 | 415818 | 1196113 |
| 5 | 420866 | 1195805 | 21 | 415663 | 1193948 | 37 | 416096 | 1196182 |
| 6 | 420789 | 1195515 | 22 | 415676 | 1194028 | 38 | 416980 | 1196380 |
| 7 | 420891 | 1194931 | 23 | 415689 | 1194073 | 39 | 417266 | 1196448 |
| 8 | 420637 | 1194818 | 24 | 415746 | 1194194 | 40 | 417731 | 1196656 |
| 9 | 420587 | 1194463 | 25 | 415896 | 1194453 | 41 | 415872 | 1195931 |
| 10 | 420659 | 1194068 | 26 | 415912 | 1194501 | 42 | 416623 | 1196085 |
| 11 | 420395 | 1194293 | 27 | 415921 | 1194565 | 43 | 416437 | 1196100 |
| 12 | 420148 | 1194360 | 28 | 415946 | 1195249 | 44 | 416540 | 1196050 |
| 13 | 420126 | 1194130 | 29 | 415807 | 1195593 | 45 | 417063 | 1195896 |
| 14 | 418744 | 1194151 | 30 | 415767 | 1195736 | 46 | 417002 | 1195785 |
| 15 | 417167 | 1194356 | 31 | 415733 | 1195892 | 47 | 417039 | 1195643 |
| 16 | 416596 | 1193942 | 32 | 415728 | 1195970 | 48 | 417034 | 1195395 |
| ចំណុច | X | Y | ចំណុច | X | Y- | ចំណុច | X | Y |
| 49 | 416935 | 1195185 | 51 | 416567 | 1194964 | 53 | 416059 | 1195211 |
| 50 | 416673 | 1194957 | 52 | 416247 | 1195024 | 54 | 415846 | 1195723 |

**មាត្រា ២ ៖**

ត្រូវបានប្រគល់អាណាត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត ធ្វើការគ្រប់គ្រង និងធ្វើប្រទានកម្មផ្ដល់ជូនប្រជាពលរដ្ឋចំនួន ៤១១ (បួនរយដប់មួយ) គ្រួសារ ដែលបានកាន់កាប់និងប្រើប្រាស់ដីនោះ ដើម្បីមានសិទ្ធិកាន់កាប់ស្របច្បាប់ ទៅតាមទំហំដីជាក់ស្តែង ដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ និងរដ្ឋបាលសុរិយោដី

បានធ្វើការអង្កេត វាស់វែង ស្របតាមនីតិវិធីនៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យទាក់ទងនឹងការងារចុះបញ្ជីដីធ្លី។

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកដីជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ត្រូវគិតបញ្ចូល និងកាត់ចេញនូវចំណែកដីមួយចំនួនដែលនឹងត្រូវរក្សាទុក សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងសង្គមក្នុងមូលដ្ឋានផ្ទាល់ ។

**មាត្រា ៣ ៖**

ក្នុងពេលរង់ចាំដំណើរការចុះបញ្ជីដីធ្លីតាមនីតិវិធីបានបញ្ចប់ជាស្ថាពរ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពតត្រូវផ្តល់ប័ណ្ណកម្មសិទ្ធិបឋមលើដីនោះ ដូចមានគម្រូក្នុងឧបសម្ព័ន្ធ III នៃអនុក្រឹត្យនេះ ដល់ប្រជាពលរដ្ឋដែលទទួលបានដី ក្នុងនោះត្រូវធ្វើប្រទានកម្មជាកម្មសិទ្ធិឯកជន លើចំណែកដីមិនលើសពី ០៥(ប្រាំ) ហិកតា លើកលែងតែដីដែលបានដាំដំណាំរួច ដូចជាកៅស៊ូជាដើម អាចផ្តល់ជាកម្មសិទ្ធិឯកជន ក្នុងទំហំមិនលើសពី ២០០ (ពីររយហិកតា) ។

**មាត្រា ៤ ៖**

ចំណែកដីនៅសល់ពីការធ្វើប្រទានកម្មដូចចែងក្នុងមាត្រា ៣ ត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពត និងអាចផ្តល់ប្រទានកម្មនូវសិទ្ធិសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ដោយត្រូវផ្តល់លិខិតបញ្ជាក់ការប្រើប្រាស់ដីរដ្ឋក្នុងរូបភាពសម្បទានដីសេដ្ឋកិច្ចខ្នាតតូច ដូចមានគម្រូក្នុងឧបសម្ព័ន្ធទី IV នៃអនុក្រឹត្យនេះ នៅក្នុងពេលរង់ចាំការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចជាផ្លូវការ ។

**មាត្រា ៥ ៖**

កម្រៃសេវាសុរិយោដី និងកាតព្វកិច្ចពន្ធផ្សេងៗដែលមានជាប់ពាក់ព័ន្ធជាបន្ទុករបស់រដ្ឋ។

**មាត្រា ៦ ៖**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧ ៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយ
- ខុទ្ទកាល័យ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១០៦ អនក.បក ចុះថ្ងៃទី ១៦ កក្កដា ឆ្នាំ២០១២
ស្តីពី ការកាត់ចេញពីដែនដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ
និងការផ្ទេរប្រធានកម្មសិទ្ធិចំនួន ១.១២៨ ហិកតា ជូនប្រជាពលរដ្ឋកាន់កាប់ប្រើប្រាស់

